# ការទាមទារជំនួយ MEDI-CAL សំរាប់កម្មវិធីផ្តល់កិច្ចថែរក្សាផ្ទាល់ខ្លួន

កម្មវិធីផ្តល់កិច្ចថែរក្សាផ្ទាល់ខ្លួន (Personal Care Services Program ឬ PCSP) ដែលផ្តល់កិច្ចថែរក្សាតាមរយៈកិច្ចជួយផ្គត់ផ្គង់ទៅដល់ផ្ទះ (In-Home Supportive Services) ក្នុងពេលឥឡូវនេះត្រូវបានបង់ប្រាក់ឱ្យដោយជំនួយផ្នែកពេទ្យនៃរដ្ឋកាលីហ្វ័រនីញ៉ា (Medi-Cal) ។

នេះគឺមានន័យថា តម្លៃសំរាប់កិច្ចថែរក្សាទាំងអស់ដែលបានផ្តល់ឱ្យលោកអ្នកបន្ទាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ១៩៩៣ អាចត្រូវបានទាមទារមកវិញដោយកម្មវិធីមេឌី–ខាល ។

**<u>អ្នកណាខ្លះដែលត្រូវបានប៉ះពាល់?</u>**

- អ្នកទទួលជំនួយ PCSP ដែលមានអាយុ៥៥ឆ្នាំ និងចាស់ជាង ។
- អ្នកទទួលជំនួយ PCSP (អាយុ៥៥ឡើង) ដែលមិនមានប្តីឬប្រពន្ធនៅរស់ គ្មានកូនអាយុតិចជាង២១ឆ្នាំ ឬគ្មានកូនពេញវ័យដែលមានភាពពិការទាំងស្រុង ។
- ប្តីឬប្រពន្ធនៃអ្នកទទួលជំនួយមេឌី–ខាល បើសិនជាការទាមទារត្រូវបានផ្តើមទាមទារជាដំបូងសំរាប់ទ្រព្យសម្បត្តិ នៅពេលដែលទ្រព្យសម្បត្តិនោះត្រូវបានគេលក់ ផ្លាស់ប្តូរម្ចាស់ ឬជាផ្ទេរទៅនឹងអ្វីមួយ ។

**<u>តើការទាមទារនៃជំនួយមេឌី–ខាលគឺជាអ្វី?</u>**

ការទាមទារនៃជំនួយមេឌី–ខាលគឺមានន័យថា ជាការទាមទារមួយដែលត្រូវបានធ្វើទៅលើទ្រព្យសម្បត្តិរបស់លោកអ្នក បន្ទាប់ពីលោកអ្នកបានស្លាប់ សំរាប់ចំនួនប្រាក់ស្មើគ្នាដែលត្រូវបានបង់ឱ្យដោយជំនួយមេឌី–ខាលដែលលោកអ្នកបានទទួល ដោយគិតបញ្ចូលទាំងកិច្ចជួយពីកម្មវិធី PCSP ។

**<u>សំគាល់</u>** :

- ការទាមទារនេះនឹងមិនត្រូវបានធ្វើចំពោះទ្រព្យសម្បត្តិនៃអ្នកទទួលជំនួយនៃកម្មវិធី PCSP ឡើយ បើសិនជាក្រុមគ្រួសារបានបង្ហាញនូវការលំបាកវេទនាយ៉ាងធ្ងន់ធ្ងរមួយ ។

**សេចក្តីប្រកាសនេះទាក់ទងតែទៅនឹងការទាមទារមកវិញនូវប្រាក់សំរាប់កិច្ចជួយ PCSP ដែលបានបង់ឱ្យដោយកម្មវិធីមេឌី–ខាល – ច្បាប់កម្មវិធីមេឌី–ខាលដែលមានពីមុនមកសំរាប់ការទាមទារមកវិញនូវប្រាក់បង់សំរាប់កិច្ចថែរក្សាដទៃទៀតនៃកម្មវិធីមេឌី–ខាលដែលលោកអ្នកទទួលគឺនៅតែអនុវត្តជាបន្ត ។**

**គោលបំណងនៃសេចក្តីប្រកាសនេះគឺដើម្បីឱ្យលោកអ្នកដឹងថាកិច្ចថែរក្សានៃកម្មវិធី PCSP ដែលលោកអ្នកទទួលក៏ស្ថិតនៅក្នុងការតម្រូវនៃច្បាប់ទាមទារប្រាក់នៃកម្មវិធីមេឌី–ខាលដែលមានពីមុនមកនោះដែរ ។**